# ការសម្ភាសន៍របស់បងស្រី យ៉ាន់ ស្រ៊ីម

កៈ អ្នកសំភាសន៍ គង់ ចាន់ណាក់　　　ខៈ អ្នកដែលត្រូវបានគេសំភាសន៍យ៉ាន់ ស្រ៊ីម

## <u>ការសម្ភាសន៍ជីវប្រវត្តិសង្ខេបរបស់ឈ្មោះ យ៉ាន់ ស្រ៊ីម</u>

សង្ខេបៈ បងស្រី យ៉ាន ស្រ៊ីម គាត់មានអាយុសែសិបបីឆ្នាំ គាត់បានកើតនៅភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ គាត់មានបងប្អូនចំនួនដប់នាក់ ហើយគាត់ជាកូនទីដប់ ជាកូនពៅ។ កាលសម័យពលពតគាត់នៅតូចអញ្ចឹងហើយ គាត់អត់សូវមានការលំបាកនោះទេ ហើយសំរាប់គាត់រាល់ថ្ងៃគាត់អត់មានធ្វើការអីទេ គាត់រស់ដោយសារក្មួយរបស់គាត់បានទៅធ្វើការនៅប្រទេសថៃហើយបានអោយគាត់ជួយមើលផ្ទះអោយគាត់។ ហើយបំណងប្រាថ្នារបស់គាត់គឺគាត់ចង់ធ្វើបុណ្យអោយសប្បាយម្តង។ ក្នុងជីវិតរបស់គាត់មានការលំបាកច្រើនតែគាត់មានការតស៊ូច្រើន ហើយគាត់មិនដែលចុះចាញ់ម្តងណាឡើយ។ធ្វើឡើងនៅភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ធ្វើឡើងនៅថ្ងៃទី២៩ ខែ០៦ ឆ្នាំ២០១៨។

កៈ ជំរាបសួរបងស្រី ខ្ញុំឈ្មោះ គង់ ចាន់ណាក់ ហើយខ្ញុំមកពីគម្រោងជីវប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា ដែលគម្រោងនឹងធ្វើឡើងដោយសាកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិក ដែលមានឈ្មោះថា សាកលវិទ្យាល័យ ប៊ី វ៉ាយ យូ ដោយសារសាកលវិទ្យាល័យមានគោលបំណងចង់ជួយថែរក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរទុក ដើម្បីទុកអោយកូនចៅជំនាន់ក្រោយរបស់ពួកយើងរៀន ហើយស្គាល់ពីប្រវត្តិរបស់ជីដូនជីតា ហើយនឹងឪពុកម្តាយ។ ហើយសំរាប់ការសម្ភាសន៍មួយនេះធ្វើ នៅភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។ ហើយយើងធ្វើការសម្ភាសន៍មួយនេះនៅ ថ្ងៃទី២៩ ខែ០៦ ឆ្នាំ២០១៨។ ហើយអញ្ចឹង សំរាប់ការសម្ភាសន៍មួយនឹងថតជាសំលេង ហើយនឹងថតជារូបភាពដើម្បីយើងផ្ញើរទៅកាន់សាកលវិទ្យាល័យដើម្បីសាកលវិទ្យាល័យអាចយកទៅដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។ ហើយអញ្ចឹង តើបងស្រីយល់ព្រមដើម្បីអោយយើងយក សំលេងហើយនឹងរូបភាពរបស់បងស្រីដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យទេបងស្រី?

ខ៖ ព្រមតើ។

ក៖ អញ្ចឹង អរគុណបងស្រី
សំរាប់បងស្រីដែលបានអនុញ្ញាតិអោយខ្ញុំយកសំលេងហើយនឹងរូបថត
របស់បងស្រីដាក់នៅលើវេបសាយរបស់សាកលវិទ្យាល័យ។
ហើយអញ្ចឹងដំបូងចង់សួរបងស្រី តើ បងស្រីមានឈ្មោះអ្វីដែរ បងស្រី?

ខ៖ ខ្ញុំឈ្មោះ យ៉ាន់ ស្រ៊ីម។

ក៖ យ៉ាន់ ស្រ៊ីម! ហើយអញ្ចឹង តើបងស្រីមានឈ្មោះហៅក្រៅទេ បងស្រី?

ខ៖ អត់មានទេ។

ក៖ អត់មានទេ មានតែឈ្មោះមួយនឹងទេបងស្រី។ ហើយអញ្ចឹង
កាលដែលបងស្រីនៅក្មេងៗគេហៅ ឈ្មោះរបស់បងស្រីថាម៉េចដែរ?

ខ៖ គេហៅតែអញ្ចឹងទេ។

ក៖ អូ! គេហៅឈ្មោះរបស់បងស្រីតែអញ្ចឹងទេ។ ហើយអញ្ចឹង
សំរាប់សព្វថ្ងៃនឹងបងស្រីមានអាយុ ប៉ុន្មានឆ្នាំហើយ បងស្រី?

ខ៖ ខ្ញុំឆ្នាំរោង អាយុសែជាងហើយ សែសិបបីឆ្នាំ។

ក៖ ហើយអញ្ចឹង តើបងស្រីមាននៅចាំថាបងស្រីបានកើតនៅក្នុងឆ្នាំណាទេ បងស្រី?

ខ៖ ខ្ញុំកើតឆ្នាំរោង។

ក៖ បងស្រីកើតឆ្នាំរោង
អញ្ចឹងបងស្រីបានកើតប្រហែលឆ្នាំមួយពាន់ប្រាំបួនរយចិតសិបប្រាំ។
ហើយអញ្ចឹងសំរាប់បងស្រីបានកើតឆ្នាំខ្មែរឆ្នាំរោង។ ហើយអញ្ចឹង
តើបងស្រីបានកើតនៅកន្លែង ណាដែរ បងស្រី?

ខ៖ ខ្ញុំកើតនៅភូមិក្បាលអូរ ឃុំដំរិល ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ។

ក៖ ហើយអញ្ចឹង សំរាប់បងស្រីមានបងប្អូនចំនួនប៉ុន្មាននាក់ដែរ បងស្រី?

ខ៖ បងប្អូនរបស់ខ្ញុំដប់នាក់ឯណោះ។

ក៖ អូ! បងប្អូនដប់នាក់។

ខ៖ កូនដូចជ្រូក។

ក៖ បងប្អូនដប់នាក់។

ខ៖ ចាំ!

ក៖ ហើយអញ្ចឹង បងស្រីជាកូនទីប៉ុន្មានដែរ នៅក្នុងក្រុមគ្រួសារ បងស្រី?

ខ៖ ខ្ញុំកូនពៅគេ។

ក៖ អូ! បងស្រីពៅគេ។ ហើយចុះសំរាប់បងប្អូនរបស់បងស្រីទាំងដប់នាក់នឹង មានស្រីប៉ុន្មាននាក់ ហើយប្រុសប៉ុន្មាននាក់ដែរ បងស្រី?

ខ៖ ស្រីបីនាក់ ហើយប្រុសប្រាំពីរនាក់។

ក៖ អូ! ប្រុសប្រាំពីរនាក់! ហើយអញ្ចឹង តើបងស្រីអាចជួយរាប់ឈ្មោះបងប្អូនរបស់បងស្រីទាំងដប់នាក់បានទេ បងស្រី?

ខ៖ បងស្រីឈ្មោះ ឈិន ជាស្រី ហើយបន្ទាប់មកទៀតបង ងុក ឈ្មោះ គឿក ឈ្មោះ ផន ហើយឈ្មោះ គោ ហើយឈ្មោះ ភាព ហើយឈ្មោះ ភា ហើយឈ្មោះស្រី ឈ្មោះស្រីហើយបានបងភាព បងភាពហើយបានបងភា បងភា ហើយបានខ្ញុំ រាប់អស់មិញនឹងវាដប់នាក់។

ក៖ ហើយអញ្ចឹង បងប្អូនរបស់បងស្រីទាំងដប់នាក់បងស្រីរាល់ថ្ងៃគាត់នៅរស់ប៉ុន្មាននាក់ដែរ បងស្រី?

ខ៖ រាល់ថ្ងៃនឹងនៅតែបីនាក់ទេ ងាប់អស់ហើយ។

ក៖ ស្លាប់អស់ប្រាំពីរនាក់ហើយ។ ស្លាប់ដោយសារមូលហេតុអ្វីដែរ បងស្រី?

ខ៖ អូ! ប៉ុន្មាននាក់នឹងស្លាប់ជំនាន់ពលពតបនឹង ទៅទ័ពរួចទៅ។

ក៖ ប្រុសៗ?

ខ៖ ចាំ! ហើយដល់ពេល នៅមួយបងខ្ញុំទើបនឹងស្លាប់គាត់ឈឺ។

ក៖ ហើយអញ្ចឹងសំរាប់បងប្អូនទាំងបីនាក់របស់បងស្រីដែលរស់នៅរាល់ថ្ងៃនឹង តើពួកគាត់រស់នៅកន្លែងណាដែរ បងស្រី?

ខ៖ បងប្អូនរបស់ខ្ញុំរស់នៅនឹងតើ។

កៈ នៅភូមិក្បាលអូរយើងនឹងទាំងអស់គ្នា?

ខៈ ចាំ! នៅភូមិក្បាលអូរទាំងអស់គ្នានឹង។

កៈ ហើយអញ្ចឹង សំរាប់សព្វថ្ងៃនេះពួកគាត់ប្រកបមុខរបរអ្វីដែរ បងស្រី?

ខៈ ខ្ញុំ ហាំ?

កៈ អត់ទេ បងប្អូនរបស់បងស្រី?

ខៈ បងប្អូនរបស់ខ្ញុំហាំ! គ្មានធ្វើអីទេ នៅមើលថៅទេនោះ
បងខ្ញុំស្រីបងគេបង្អស់នៅមើលថៅទេ។

កៈ នៅមើលថៅទេ?

ខៈ ចាំ!

កៈ ហើយអញ្ចឹង សំរាប់ម្ដាយរបស់បងស្រីគាត់មានឈ្មោះអ្វីដែរ បងស្រី?

ខៈ ម្ដាយរបស់ខ្ញុំគាត់ឈ្មោះ ជៀប តូ។

កៈ ជៀប តូ!

ខៈ ចាំ!

កៈ បាទ បាទ!! ហើយអញ្ចឹង
សំរាប់សព្វថ្ងៃនេះម្ដាយរបស់បងស្រីគាត់មានអាយុប៉ុន្មានឆ្នាំហើយ បងស្រី?

ខៈ ម្ដាយរបស់ខ្ញុំគាត់ស្លាប់បាត់ហើយ មិនដឹងអាយុប៉ុន្មានទេ គាត់ស្លាប់យូរហើយ។

កៈ គាត់ស្លាប់យូរហើយ បងស្រី!

ខៈ យូរហើយ! ខ្ញុំមិនដឹងទេព្រោះអីខ្ញុំនៅតូចដែរ។

កៈ ហើយអញ្ចឹង តើគាត់បានកើតនៅពេលណា បងស្រីមានដឹងទេ?

ខៈ ម៉ែរបស់ខ្ញុំហាំ?

កៈ ហ្នឹងហើយ!

ខៈ បើខ្ញុំអត់ដឹងផង។

កៈ អត់ដឹងផង បងស្រី?

ខៈ ចា៎! ខ្ញុំអត់ដឹងទេ។

កៈ ហើយអញ្ចឹង តើម្ដាយរបស់បងស្រីគាត់មានស្រុកកំណើតនៅកន្លែងណាដែរ បងស្រី?

ខៈ ស្រុកកំណើតគាត់នៅនឹងតើពូ។

កៈ នៅនឹងដែរ នៅនឹងភូមិក្បាលអូរនឹង?

ខៈ នៅនឹងភូមិក្បាលអូរនឹងដែរ។

កៈ ហើយអញ្ចឹង តើគាត់កើតឆ្នាំអីដែរ នៅក្នុងឆ្នាំខ្មែរយើង?

ខៈ គាត់កើតឆ្នាំជូត។

កៈ អូ! គាត់កើតឆ្នាំជូតហ៎!

ខៈ ចា៎! ជូតគាត់ជូតយូរហើយ។

កៈ បាទ! បាទ! ហ្នឹងហើយ! ហើយអញ្ចឹង តើគាត់បានស្លាប់ពេលណា បងស្រីមានដឹងទេ?

ខៈ គាត់ស្លាប់យូរហើយ យូរហើយយាយ។

កៈ យូរហើយ!

ខៈ មើល គាត់ស្លាប់មុនមីវ៉ា វាអាយុម្ភៃជាងទៀតហើយឥលូវ ចាប់ជាតិមកមីវ៉ាក្មួយរបស់ខ្ញុំជាងម្ភៃឆ្នាំហើយ។

កៈ ជាងម្ភៃឆ្នាំហើយ!

ខៈ មីនឹងអាយុជាមួយម្ភៃឆ្នាំហើយ។

កៈ ហើយអញ្ចឹង ពេលម្ដាយរបស់បងស្រីស្លាប់នឹង បងស្រីប្រហែលអាយុប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំអាយុដប់ប្រាំពីរឆ្នាំ។

កៈ ដប់ប្រាំពីរឆ្នាំហ៎?

ខៈ ចា៎!

កៈ បាទ! បាទ!! ហើយចុះ សំរាប់ពេលដែលម្ដាយរបស់បងស្រីគាត់នៅរស់នឹង តើគាត់រកស៊ីអ្វីដែរ បងស្រី?

ខៈ ម្ដាយរបស់ខ្ញុំកាលគាត់នៅរស់នឹង គាត់ទូលត្រីងៀត ត្រីឆ្អើរ ដើរលក់ដូរអង្ករយកមកចិញ្ចឹមកូន អញ្ចឹង។

កៈ អូ! បាទ! បាទ!!

ខៈ អត់មានអីទេម៉ែរបស់ខ្ញុំពីមុនមក គ្មានអីទេ សួរតែយាយដឹងហើយ លក់ដូរត្រីងៀត ត្រីឆ្អើរ ទៅគីឡូ ធ្លាក់អីណាអីណី ស្រុកគេស្រុកឯងណោះ
ដូរអង្ករដូរស្រូវយកមកចិញ្ចឹមកូននឹង។

កៈ ហ្នឹងហើយ! ហើយអញ្ចឹង សំរាប់ម្ដាយរបស់បងស្រីគាត់ជាមនុស្សមានចរិតបែបណាដែរ បងស្រី?

ខៈ គាត់គ្មានចរិតរបៀបម៉េចផង។

កៈ គាត់ស្លូតបូត ឬក៏ម៉េចដែរ?

ខៈ គាត់ស្លូតក៏មិនស្លូត កាចក៏មិនកាច ល្មមធម្មតា។

កៈ ហើយចុះ សំរាប់ឪពុករបស់បងស្រីគាត់មានឈ្មោះអ្វីដែរ បងស្រី?

ខៈ ឪពុករបស់ខ្ញុំគាត់ឈ្មោះ ម៉ម យ៉ាន់។

កៈ ម៉ម យ៉ាន់។ ហើយអញ្ចឹង
សំរាប់សព្វថ្ងៃនឹងឪពុករបស់បងស្រីគាត់មានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ គាត់ស្លាប់បាត់ដែរហើយ។

កៈ គាត់ស្លាប់បាត់ហើយន៎ បងស្រី!

ខៈ គាត់កើតឆ្នាំមមែ។

កៈ អូ! អញ្ចឹងឪពុករបស់បងស្រីគាត់កើតឆ្នាំមមែ។

ខៈ ចាំ! ខ្ញុំមិនដឹងដែរ មិនដឹងគាត់ឆ្នាំអី ឆ្នាំអី បើខ្ញុំតូចជាងគេ។

កៈ ហើយអញ្ចឹង សំរាប់ឪពុករបស់បងស្រីគាត់បានកើតនៅកន្លែងណាដែរ?

ខៈ គាត់កើតនៅនឹងភូមិក្រពើសារ ភូមិគាត់នៅក្រពើសារនឹង។

កៈ ភូមិក្រពើសារ ឃុំដំរិលយើងនឹងហ៎?

ខៈ ចា៎! ជាមួយគ្នានឹង។

កៈ បាទ! បាទ!! ហ្នឹងហើយ! ហើយអញ្ចឹង តើគាត់ស្លាប់ពេលណា បងស្រីដឹងទេ?

ខៈ ទេ តានឹងគាត់ស្លាប់យូរដែរហើយ។

កៈ គាត់ស្លាប់យូរដែលហើយ! ហើយចុះ ពេលដែលឪពុករបស់បងស្រីគាត់ស្លាប់នឹង តើបងស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

ខៈ ខ្ញុំអាយុម្ភៃបីឆ្នាំ។

កៈ ម្ភៃបីឆ្នាំហ៎?

ខៈ ចា៎! ពេលដែលឪពុករបស់ខ្ញុំស្លាប់នឹង ខ្ញុំអាយុម្ភៃបីឆ្នាំ។

កៈ អញ្ចឹងហ៎! អញ្ចឹងមានន័យថា ឪពុករបស់បងស្រីគាត់បានស្លាប់ក្រោយម្ដាយទេ?

ខៈ ក្រោយទេ!

កៈ អូ! ក្រោយទេ យាយស្លាប់មុន! បាទ! បាទ!!

ខៈ កាលខ្មោចម្ដាយរបស់ខ្ញុំស្លាប់ ខ្ញុំអាយុដប់ប្រាំពីរឆ្នាំ។

កៈ ដល់ពេលបងស្រីអាយុម្ភៃបីឆ្នាំឪពុកស្លាប់។ ហើយអញ្ចឹង សំរាប់ពេលដែលឪពុករបស់បងស្រី នៅរស់គាត់រកស៊ីអីដែរ បងស្រី?

ខៈ ឪពុករបស់ខ្ញុំគាត់គ្មានរកអីទេ គាត់ធ្វើតែស្រែបន្តិចបន្តួចចឹង គាត់មិនដែលទៅរកស៊ីជំនួញជួញដូរស្អីទេ។

កៈ ហើយអញ្ចឹង សំរាប់ឪពុករបស់បងស្រីគាត់ជាមនុស្សបែបណាដែរ ចរិត? គាត់ស្លូតបូតដែរ?

ខៈ គាត់មិនដែលទៅអាក្រក់អីទេ មិនទៅរករឿងពីណាគេទេ គាត់ស្លូតបូត។

កៈ ទៀងត្រង់ អីចឹងទៅ!

ខៈ ចា៎! មិនដែលខូចខិលអីនឹងគេទេ ឪពុករបស់ខ្ញុំនោះ។

កៈ បាទ! បាទ!! ហ្នឹងហើយ! ហើយអញ្ចឹង
បងស្រីធ្លាប់មានអនុស្សាវរីយ៍អីល្អៗជាមួយឪពុកម្ដាយទេ បងស្រី?

ខៈ អើ! ដូចថាវាមានមាត់ធំមាត់តូចដែរ គ្មាននរណាអត់បានទេ ដល់ពេលខឹងទៅ
មួយពេលខឹងទៅ ថាគំហិតគំហាកដាក់គាត់បន្តិចដែរ ដល់ពេលរួចទៅលែងអីវិញទៅ។ អើ!
មនុស្សនៅជាមួយគ្នា។

កៈ ហើយអញ្ចឹង
សំរាប់ឪពុកម្ដាយរបស់បងស្រីគាត់ធ្លាប់ប្រាប់បងស្រីពីជីវិតគាត់កាលគាត់នៅ
ក្មេងៗទេបងស្រី?

ខៈ គាត់អត់ដែលនិយាយប្រាប់ខ្ញុំទេ។

កៈ អត់ដែលនិយាយប្រាប់ន៎ បងន៎! ហ្នឹងហើយ! ហើយអញ្ចឹង សំរាប់បងស្រី
តើបងស្រីមានចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់បងស្រីទេ?

ខៈ បើជីដូនជីតាខាងម្ដាយរបស់ខ្ញុំឈ្មោះ តាជៀប យាយជួន។

កៈ តាជៀប យាយជួន!

ខៈ តែខ្ញុំអត់បានឃើញមុខគាត់ទេណា លឺតែម្ដាយរបស់ខ្ញុំនិយាយទេ។

កៈ អូ! បាទ! បាទ!!

ខៈ ខ្ញុំអត់ដឹងទេ ខ្ញុំអត់បានឃើញមុខយាយទេ។

កៈ អត់ដែលបានជួបមុខគាត់ទេ ន៎! ហើយអញ្ចឹង
សំរាប់បងស្រីចាំឈ្មោះជីដូនជីតាខាងឪពុករបស់បងស្រីទេ?

ខៈ ខាងឪពុកនឹងឈ្មោះ តាម៉ម យាយហួន។

កៈ តាម៉ម យាយហួន។ ហើយអញ្ចឹង តើបងស្រីធ្លាប់ជួបជាមួយគាត់ទេ?

ខៈ ខ្ញុំអត់ដែលឃើញមុខដែរ ខ្ញុំអត់ដែរឃើញទេ។

កៈ អញ្ចឹងបានន័យថាពេលបងស្រីកើតមកពួកគាត់បានស្លាប់អស់ហើយ?

ខ៖ ខ្ញុំអត់ដែលដឹងផងនឹង ខ្ញុំគ្រាន់តែលឺម៉ែរបស់ខ្ញុំគាត់និយាយថា យាយរបស់ខ្ញុំខាងតាឈ្មោះយាយម៉ម តាហួន គាត់គ្រាន់តែប្រាប់អញ្ចឹង។

ក៖ គាត់គ្រាន់តែប្រាប់អញ្ចឹង!

ខ៖ តែខ្ញុំមិនបានឃើញមុខទេ យាយតានឹងក៏គាត់កើតនៅនឹងដែរ ភូមិគាត់នៅនឹងតើ។

ក៖ ហើយអញ្ចឹង តើក្រុមគ្រួសាររបស់បងស្រីរស់នៅក្នុងខេត្តនេះអស់រយៈពេលប៉ុន្មានឆ្នាំហើយ បងស្រី?

ខ៖ ខ្ញុំនៅតាំងពីកើតមកនឹងហើយ ខ្ញុំនៅរហូត។

ក៖ ហើយអញ្ចឹង បងស្រីមានសាច់ញាតិដទៃដែលរស់នៅក្រៅប្រទេសខ្មែរយើងទេ?

ខ៖ ខ្ញុំអត់ដែរមានទេ។

ក៖ អត់ដែរមានសោះ បងស្រីណាំ! ហើយអញ្ចឹងសំរាប់ស្វាមីរបស់បងស្រីគាត់មានឈ្មោះអ្វីដែរ?

ខ៖ អ្វើ! ខ្ញុំខ្ជិលចង់និយាយប្រាប់ម៉ងដល់ពេលបែកបាក់គ្នាអស់ហើយ។

ក៖ បែកបាក់គ្នាហើយ បងស្រី?

ខ៖ ខ្ញុំលែង។

ក៖ នៅតែម្នាក់ឯងទេបងស្រីណាំ! ហើយអញ្ចឹង បងស្រីមានកូនទេ បងស្រី?

ខ៖ ខ្ញុំអត់មានទេ។

ក៖ អត់មានទេ បងស្រីណាំ! ហើយអញ្ចឹង តើបងស្រីចេះអាននិយសរសេរអក្សរខ្មែរទេ បងស្រី?

ខ៖ ខ្ញុំអត់ចេះទេ។

ក៖ អត់ចេះទេ បងស្រី?

ខ៖ ខ្ញុំអត់ចេះមែន! ចេះស្អីបើរៀនដល់ថ្នាក់ទីពីរ ហើយដល់ពេលទទួលម៉ែឈឺទៅ។

ក៖ នៅមើលថៃគាត់ទៅ?

ខ៖ នៅមើលគាត់នឹង ទៅលក់វេរយកលុយយកមកចិញ្ចឹមគាត់ទៅ
លែងបានទៅរៀនបណ្ដោយ។

ក៖ ហើយអញ្ចឹង តើបងស្រីចេះភាសាផ្សេងក្រៅពីភាសាខ្មែរទេ បងស្រី?

ខ៖ អូ! អត់ចេះទេ។

ក៖ អត់ចេះទេ បងស្រី?

ខ៖ ចាំ! អត់ចេះទេ។

ក៖ ហើយអញ្ចឹង តើបងស្រីរៀនដល់ថ្នាក់ទីប៉ុន្មានដែរ បងស្រី?

ខ៖ រៀនដល់ថ្នាក់ទីពីរ។

ក៖ រៀនដល់ថ្នាក់ទីពីរដែរ បងស្រី?

ខ៖ ថ្នាក់ទីពីរ ស្រះអ ស្រះអា មិនទាន់ចប់ផង។

ក៖ ហ្នឹងហើយ! ហើយអញ្ចឹង សំរាប់បងស្រីរៀននៅសាលារៀនណាដែរ បងស្រី?

ខ៖ នឹងសាលាដំរិលយើងនឹង។

ក៖ សាលាដំរិលយើងនឹង បងស្រី?

ខ៖ ចាំ!

ក៖ សាលានឹងឈ្មោះ សាលាបឋមសិក្សាដំរិលចឹង ឬបងស្រី?

ខ៖ ចាំ!

ក៖ ហើយអញ្ចឹង សំរាប់បងស្រីមានមិត្តភក្តិស្និតស្នាលដែលធំធាត់មកជាមួយគ្នាទេ
បងស្រី?

ខ៖ អត់ដែរមានទេ
ព្រោះអីខ្ញុំអត់ដែលបានដើរទៅណាអោយស្គាល់មិត្តភក្តិឯណាឯណីផង។

ក៖ អញ្ចឹងហ៎! នៅតែក្នុងភូមិយើងនឹង។

ខ៖ ចាំ! ខ្ញុំនៅតែនឹង។

ក៖ ហើយអញ្ចឹង សំរាប់រាល់ថ្ងៃនឹងបងស្រីមានធ្វើស្រែចំការទេ បងស្រី?

ខ៖ ខ្ញុំអត់មានធ្វើស្រែទេ ស្ងម្បីតែស្រែក៏គ្មានតែនឹងអីរាល់ថ្ងៃនឹងនោះ។

ក៖ អញ្ចឹងហ៎! អត់មានស្រែអត់អីទេណ៎!

ខ៖ អត់មានទេ។

ក៖ ហើយអញ្ចឹង សំរាប់បងស្រីរាល់ថ្ងៃបងស្រីប្រកបមុខរបរអីដើម្បីចិញ្ចឹមជីវិតដែរ?

ខ៖ អត់មានប្រកបមុខរបរអីទេរាល់ថ្ងៃនឹង ក្មួយវាទៅប្រទេសថៃនឹងវាអោយដេកផ្ទះវានឹង
អង្គុរគេនឹងគេអោយស៊ីរាល់ថ្ងៃនឹង។

ក៖ អញ្ចឹងមានន័យថា ក្មួយនឹងគេអោយយើងជួយចាំផ្ទះទៅ
ហើយគាត់ដូចជាផ្គត់ផ្គង់អង្ករម្ហូបអោយ យើងអញ្ចឹងទៅ។

ខ៖ បើខ្ញុំ ខ្ញុំអត់បានទៅរកស៊ីអីនឹងគេទេ ស្រែក៏គ្មានអីក៏គ្មាន។

ក៖ ហើយអញ្ចឹងសំរាប់បងស្រីគិតថា
ជីវិតរបស់បងស្រីតាំងពីក្មេងរហូតមកដល់ពេលនេះមានការផ្លាស់ប្តូរទេ បងស្រី?

ខ៖ ថាចង់ផ្លាស់ប្តូរដែរ តែមិនដឹងថាផ្លាស់ប្តូរទៅខាងណា។

ក៖ ប៉ុន្តែជីវិតពីដើមមកលំបាក ហើយចុះឥលូវនៅតែពិបាកដដែល?

ខ៖ ពិបាកដដែល។

ក៖ អញ្ចឹង អត់មានការផ្លាស់ប្តូរអីទេ?

ខ៖ អើយបើនៅតែពិបាកអញ្ចឹង ផ្លាស់ប្តូរទៅណា ងាកទៅកូនក៏គ្មាន ស្រែក៏គ្មាន។

ក៖ ហើយអញ្ចឹង សំរាប់ម្ហូបវិញ បងស្រីមានម្ហូបណាដែលបងស្រីចូលចិត្តហូបជាងគេទេ?

ខ៖ បើនិយាយពីរឿងម្ហូប ខ្ញុំពិបាកណាស់និយាយពីរឿងម្ហូបជាមួយខ្ញុំនឹង
សាច់ក៏ហូបមិនឆ្ងាញ់ ត្រីក៏ហូបមិនឆ្ងាញ់ វាមិនដឹងថាហូបម្ហូបអីអោយជំណ្ងល។

ក៖ ហើយអញ្ចឹងសំរាប់ល្បែងប្រជាប្រិយខ្មែរយើងដូចជា បោះឈូង បោះអង្គញ់
ទាញព្រ័ត្រអី តើបងស្រីធ្លាប់មានចូលចិត្តលេងល្បែងណាទេ តាំងពីក្មេងមក?

ខ៖ អត់ទេពីក្មេងមកខ្ញុំចូលចិត្តលេងបោះឈូងដែរ។

កៈ ចូលចិត្តលេងបោះឈូង បងស្រីហ៎!

ខៈ បោះឈូង បោះអង្គញ់ លេងដែលពេលខែចូលឆ្នាំ។

កៈ ហើយអញ្ចឹងសំរាប់បទចម្រៀងវិញ មានបទចម្រៀងណាដែលបងស្រីចូលចិត្តស្តាប់ទេ បងស្រីតាំងពីក្មេងមក?

ខៈ បើបទចម្រៀង បើនិយាយអោយចំទៅ បទណាក៏ដោយអោយតែគេចាក់ ខ្ញុំចង់តែស្តាប់។

កៈ ចង់ស្តាប់ទាំងអស់!

ខៈ ភ្លេងការក៏ដោយ រាំវង់ក៏ដោយ បទញាក់ក៏ដោយអីក៏ដោយ ស្តាប់ទាំងអស់។

កៈ ស្តាប់ទាំងអស់ណ៎ បងស្រីណ៎!

ខៈ ចា៎! អោយតែគេចាក់។

កៈ ហើយអញ្ចឹង នៅក្នុងក្រុមគ្រួសាររបស់បងស្រីមាននរណាមួយគាត់ចេះលេងឧបករណ៍ភ្លេងទេ បងស្រី?

ខៈ អត់មានទេ។

កៈ អត់មានអ្នកចេះទេ បងស្រី!

ខៈ កូនចៅរបស់ខ្ញុំទាំងអស់ កូនក្មួយរបស់ខ្ញុំអត់មានចេះទេ។

កៈ ហើយអញ្ចឹងសំរាប់ផ្ទះរបស់បងស្រីមានលក្ខណៈដូចម្តេចដែរ ពេលដែលបងស្រីនៅក្មេងៗ?

ខៈ សួរតែយាយទៅ ផ្ទះតូច។

កៈ ផ្ទះនឹង ផ្ទះទាមជាប់ដី ឬផ្ទះខ្ពស់ដែរ?

ខៈ មិនមែនផ្ទះទាមទេ ផ្ទះកាំជណ្តើរបី។

កៈ កាំជណ្តើរបីកាំ?

ខៈ ចា៎! កាំជណ្តើរបីកាំតូចមួយគ្រាន់នៅបាំងភ្លៀង។

កៈ ហើយអញ្ចឹង សំរាប់ផ្ទះមួយនឹង តើនរណាគេជាអ្នកធ្វើដែរ បងស្រី?

ខ៖ កាលនឹងម្ដាយរបស់ខ្ញុំ។

ក៖ ម្ដាយរបស់បងស្រីគាត់ជាអ្នកធ្វើហ៎?

ខ៖ ចា៎!

ក៖ ហើយសំរាប់ផ្ទះនឹង សំភារៈសំរាប់ធ្វើផ្ទះនឹងគាត់បានមកពីណាដែរ បងស្រី?

ខ៖ ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំកើតមកឃើញផ្ទះនឹងតែម្ដង។

ក៖ កើតមកឃើញផ្ទះនឹងនៅផ្ទះនឹងតែម៉ងណ៎ បងស្រីណ៎
អត់ដឹងថាគាត់បានសំភារៈមកពីណាទេ?

ខ៖ ចា៎! ខ្ញុំអត់ដឹងទេ។

ក៖ ហើយអញ្ចឹងសំរាប់បងស្រី
មានដូចជាជំនាញដែលបន្តវេនពីក្រុមគ្រួសាររបស់បងស្រីដូចជា វេញវល្លិ៍ផ្ដៅ
ឬក៏ធ្វើស្ករត្នោត ឬក៏ត្បាញក្រមា ត្បាញហូលទេ បងស្រី?

ខ៖ ខ្ញុំអត់ដែទេ។

ក៖ អត់ដែរមានទេបងស្រី!
ហើយអញ្ចឹងសំរាប់ជីវិតរបស់បងស្រីមានបានឆ្លងកាត់សម័យសង្គ្រាមទេ បងស្រី?

ខ៖ ខ្ញុំនៅតូចទេកាលនឹង។

ក៖ កាលនោះអ្នកមីងនៅតូចទេ?

ខ៖ ចា៎!

ក៖ អាយុប្រហែលប៉ុន្មានឆ្នាំ កាលនោះបងស្រី?

ខ៖ ខ្ញុំឆ្នាំរោង កាលសង្គ្រាមខ្ញុំនៅតូច។

ក៖ ប្រហែលប៉ុន្មានឆ្នាំដែរ ពីរឆ្នាំបីឆ្នាំ ឬក៏យ៉ាងម៉េចដែរ?

ខ៖ មួយឆ្នាំពីរឆ្នាំ ឆ្នាំរោង ហ្នឹងហើយ ពីរបីឆ្នាំនឹង ចូលបីឆ្នាំ ខ្ញុំម៉េចដឹង។

ក៖ អូ! នៅតូចពេក អត់ដឹងថាមានការលំបាកអីខ្លះទេ?

ខ៖ ខ្ញុំអត់ដឹងទេ។

កៈ បងប្អូនរបស់បងស្រីធ្លាប់ឆ្លងកាត់សង្គ្រាម?

ខៈ ចាំ!

កៈ ដូចជាមានអ្នកស្លាប់ក្នុងសម័យសង្គ្រាមដែរ?

ខៈ មាន បងខ្ញុំទៅទ័ពនោះ។

កៈ ទៅទ័ពហើយស្លាប់ក្នុងសម័យសង្គ្រាមនឹងតែម្តង ស្លាប់ក្នុងសមរភូមិនឹងតែម្តង ហើយបងស្រីនៅតូចៗអត់បានឆ្លងកាត់។

ខៈ ខ្ញុំ៣គេ ខ្ញុំអត់ដែរដឹងផង។

កៈ ហើយអញ្ចឹងសំរាប់បងស្រីធ្លាប់មានបទពិសោធន៍ល្អៗ ដូចជា រៀបអាពាហ៍ពិពាហ៍កូនចៅ រៀបអាពាហ៍ពិពាហ៍បងប្អូន ឬក៏បុណ្យទានអីនៅក្នុងផ្ទះទេ បងស្រី?

ខៈ ខ្ញុំអត់ដែលមានរៀបនៅនឹងផ្ទះរបស់ខ្ញុំទេ រៀបតែនៅនឹងផ្ទះបងប្អូនទេ រៀបអាពាហ៍ពិពាហ៍កូនចៅនឹងណា។

កៈ ហ្នឹងហើយ! តែបងស្រីបានចូលរួមជាមួយនឹងគេដែរ?

ខៈ អ្ហឺ! ខ្ញុំទៅរៀបជាមួយនឹងគេនឹង។

កៈ ជួយគេអីចឹងទៅ?

ខៈ ចាំ!

កៈ ហើយអញ្ចឹង ពេលមានកម្មវិធីនឹងម្តងៗ តើបងស្រីមានអារម្មណ៍យ៉ាងម៉េចដែរ បងស្រី?

ខៈ ខ្ញុំដូចថា បើបានបងប្អូនរៀបចឹងទៅនឹង ខ្ញុំអារម្មណ៍សប្បាយ។

កៈ សប្បាយ ទៅជួយគេតែម្តងបងស្រី?

ខៈ ហ្នឹងហើយ! កូនក្មួយវាហៅទៅ បងប្អូនហៅទៅ អារម្មណ៍សប្បាយទៅ ដល់ខ្លួនឯងអត់មានកូនអីនឹងគេ។

កៈ អត់កូនអីនឹងគេ?

ខៈ ចាំ!

កៈ ទៅជួយកូនក្មួយចឹងទៅ! ហើយអញ្ចឹងសំរាប់ពេលបងស្រីនៅក្មេងៗ
តើបងស្រីធ្លាប់មានក្តីសង្ឃឹមថា ពេលធំឡើងបងស្រីចង់ធ្វើអ្វីមួយទេ បងស្រី?

ខៈ គោលបំណងវាចង់ណាស់ ប៉ុន្តែដល់ឥលូវវាប៉ងអត់បានព្រោះយើងអត់មាន
គោលបំណងរបស់ខ្ញុំថា បើសិនជាខ្ញុំមានលុយខ្ញុំធ្វើបុណ្យអោយសប្បាយម្តង
គោលបំណងរបស់ខ្ញុំ។

កៈ អូ! គោលបំណងរបស់បងស្រីចង់ធ្វើបុណ្យ។

ខៈ ចាំ! ប៉ុន្តែធ្វើម៉េចបើយើងអត់មាន ដល់អត់មានទៅបានអី។

កៈ អញ្ចឹងរាល់ថ្ងៃនឹងរស់នៅដោយសារក្មួយជួយឧបត្ថម្ភ។ ហើយអញ្ចឹង
តើគាត់ផ្ញើរមករាល់ខែ ឬក៏យ៉ាងម៉េចដែរ បងស្រី?

ខៈ អត់ទាន់ផ្ញើរមកទេ ព្រោះអីគ្នាទើបនឹងទៅទេ។

កៈ ទៅធ្វើការនៅឯណាវិញ បងស្រី?

ខៈ ធ្វើការនៅប្រទេសថៃ។

កៈ ហើយអញ្ចឹង ក្មួយនឹងនៅប្រទេសថ្ងៃនឹង គាត់ធ្វើការងារអ្វីដែរ បងស្រី?

ខៈ មិនតាំងបានសួរវាផងពេលគេមកនឹង វាទើបនឹងទៅនឹង
ទៅនឹងដោយសារជំពាក់គេដែរនឹងបានគ្នាទៅនឹង រួចទៅអោយខ្ញុំទៅចាំផ្ទះអោយ
ខ្ញុំទៅចោលផ្ទះខ្លួនឯង ដូចដែលខ្ញុំថាផ្ទះខ្ញុំតូចមួយនឹង ទៅចាំផ្ទះអោយវានឹង
ទៅចោលផ្ទះខ្លួនឯងនឹង។

កៈ ហើយអញ្ចឹងសំរាប់បងស្រី
បើសិនជាបងស្រីចង់ផ្តាំផ្ញើរទៅកាន់កូនចៅជំនាន់ក្រោយរបស់បង
តើបងស្រីចង់ផ្តាំផ្ញើរអ្វីខ្លះដល់ពួកគាត់ បងស្រី?

ខៈ អ្ហើ! ចង់ផ្តាំផ្ញើរថា អោយប្រឹងរកស៊ីទៅ បានលុយយកមកដោះដូរគេចឹង
គ្រាន់តែប្រាំផ្ញើរប៉ុណ្ណឹង អោយប្រឹងរកស៊ីទៅ អោយប្រឹងរៀនប្រឹងសូត្រ កុំអោយវាល្ងង់ដូចខ្ញុំ
បើគេរៀនចេះដឹងទៅគេបានទៅប្រទេសគេឯណាឯណីទៅបានប្រាក់ខែច្រើន
អោយចៅប្រឹងរៀនទៅរាល់ថ្ងៃនឹង ចេះតែប្រឹងមាត់សំឡុតចៅអាតូចៗនឹង
ចៅនឹងចៅកូនក្មួយទេ មិនមែនចៅខ្លួនឯងទេ។

កៈ ហើយអញ្ចឹងសំរាប់បងស្រី បើសិនជាបងស្រីចង់អោយកូនចៅរបស់បងស្រីជៀសវាង
តើបងស្រីចង់អោយគាត់ជៀសវាងពីអ្វីខ្លះដែរ?

ខ៖ ចង់អោយពួកគាត់ជៀសវាងអារឿងថ្នាំញៀន កុំអោយវាប្រព្រឹត្តអារឿងថ្នាំញៀន ស្រាល្បែងស៊ីសងនឹង កុំអោយវាប្រឹងប្រព្រឹត្តអាល្បែងចឹងៗ អោយវាប្រឹងរៀនសូត្របានទៅស្រុកគេស្រុកឯង ប្រទេសគេអោយបានលុយយកមកដោះស្រាយម៉ែឪ។

ក៖ សំរាប់ខ្ញុំចុងក្រោយបង
អរគុណសំរាប់បងដែលបានអនុញ្ញាតិអោយខ្ញុំសម្ភាសន៍អំពីជីវប្រវត្តិរបស់បងចឹង ខ្សែជីវិតរបស់បងដែលពិបាកចឹង ហើយអញ្ចឹងជាចុងក្រោយ ខ្ញុំសូមជូនពរបង សូមអោយបងមានសុខភាពល្អ មានកំលាំងមាំមួន មានប្រាជ្ញាវៀងវៃ ហើយអោយបងស្រីជៀសផុតពី ជម្ងឺសង្កាត់ទាំងឡាយអោយមានសុខភាពល្អទៅ ហើយក៏សូមជូនពរដល់កូនចៅរបស់បងជំនាន់ក្រោយសូមអោយពួកគាត់មានសុខភាពល្អ មានកំលាំងមាំមួន មានប្រាជ្ញាវៀងវៃ ហើយជូនពរ អោយគាត់ជោគជ័យរាល់ការងារ មុខរបររកស៊ីរាល់ថ្ងៃ អោយជៀសផុតពីសត្រូវដែលមានបំណងមកយាយី សូមអោយជៀសផុតកុំអោយមានសត្រូវមានអីចឹងណា អោយជោគជ័យរាល់ការងារ ប្រកបមុខរបររកស៊ីអោយរកស៊ីចេះតែមានបានទៅមុខរហូតអញ្ចឹងទៅ កុំអោយរកទៅចេះតែខាត អីចឹងណាស់ដើម្បីគាត់អាចជួយបងស្រីមានជីវភាពល្អប្រសើរជាងនឹងទៀត។
អរគុណច្រើន។